Sacombank

# គោលការណ៍ និងលក្ខខណ្ឌ

## របស់កម្មវិធីប្រូម៉ូសិនជាមួយប័ណ្ណឥណទានវីសា

I. **ផលិតផល៖** ប័ណ្ណឥណទានវីសារបស់ធនាគារសាខម (ខេមបូឌា) ភីអិលស៊ី។

II. **រយៈពេលនៃការអនុវត្ត៖** ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៤។

III. **ព័ត៌មានលម្អិតអំពីកម្មវិធីប្រូម៉ូសិន៖**

| កម្មវត្ថុ | ព័ត៌មានលម្អិត |
|---|---|
| **អតិថិជនថ្មី** | (see table below) |
| **គ្រប់ម្ចាស់ប័ណ្ណ** | (see tables a. and b. below) |

**អតិថិជនថ្មី**

| ការផ្ដល់ជូន | ប័ណ្ណវីសាក្លាស៊ីក | ប័ណ្ណវីសាផ្លាទីនីម |
|---|---|---|
| ពេលចេញប័ណ្ណ | • **មិនគិតកម្រៃសេវាសម្រាប់ឆ្នាំដំបូង**សម្រាប់ប័ណ្ណឥណទានវីសាមិនមានទ្រព្យធានា (Unsecured credit card) ។<br>• **មិនគិតកម្រៃសេវាធ្វើឯកសារ**សម្រាប់ប័ណ្ណឥណទានវីសាមានទ្រព្យធានា (Secured credit card) ។ | |
| ពេលប័ណ្ណដំណើរការ | • **ទទួលបានសំបុត្រ E-ticket ចំនួន ១កូដ** នៅរោងភាពយន្ត Legend។ | • **ទទួលបានប័ណ្ណសមាជិកតម្លៃ ១០ដុល្លារចំនួន១** នៅកាហ្វេ Brown។ |

**គ្រប់ម្ចាស់ប័ណ្ណ**

a. **រីករាយជាមួយការផ្ដល់ជូនបញ្ចុះតម្លៃ៖**

| ការផ្ដល់ជូន | ប័ណ្ណវីសាខ្លាស៊ីក | ប័ណ្ណវីសាផ្លាទីនីម |
|---|---|---|
| **foodpanda app** | • **ទទួលបានការបញ្ចុះតម្លៃ២ដុល្លារភ្លាមៗ** រាល់ការកម្មង់អាហារយ៉ាងតិច ៥ដុល្លារ នៅលើកម្មវិធី foodpanda app (អនុវត្តចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៤ រហូតដល់ ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤) ។ | |
| **សេវាបង់រំលស់ អត្រាការប្រាក់0%** | • **មិនគិតសេវា**បង់រំលស់ ក្នុងឱកាសខួបលើកទី១៥ របស់ធនាគារ សាខមប៊ែង ខេមបូឌា (អនុវត្តក្នុងអំឡុងពេល៣០ថ្ងៃដំបូង រហូតដល់ថ្ងៃទី២០ ខែ កក្កដា ឆ្នាំ២០២៤) ។<br>• **បញ្ចុះ៥០%ថ្លៃសេវា**សម្រាប់រយៈពេលកម្មវិធីប្រូម៉ូសិនដែលនៅមានសុពលភាព។ | |

b. **កម្មវិធីណែនាំ៖**

| ការផ្ដល់ជូន | សម្រាប់អ្នកណែនាំ |
|---|---|
| ការផ្ដល់ជូន | • ទទួលបានសំបុត្រ E-ticket ចំនួន១គូ នៅរោងភាពយន្ត Legend ចំពោះរាល់ប័ណ្ណបានដំណើរការ (Activate)ជោគជ័យ។ |

IV. **គោលការណ៍ និងលក្ខខណ្ឌ៖**

**1- សម្រាប់អតិថិជនថ្មី៖**

- **អតិថិជនថ្មី៖** គឺជាអតិថិជនមិនធ្លាប់មានប័ណ្ណឥណទានវីសារបស់ធនាគារ សាខមប៊ែង ខេមបូឌា ពីមុនមក ឬសម្រាប់អតិថិជនចាស់ដែលធ្លាប់មានប័ណ្ណឥណទានវីសារបស់ធនាគារ សាខមប៊ែង ខេមបូឌា អាចទទួលបានប្រូម៉ូសិនដូច "អតិថិជនថ្មី" ប្រសិនបើបិទប័ណ្ណមុន ថ្ងៃទី០១ ខែមករា ឆ្នាំ២០២៤។

- អតិថិជនថ្មី ដែលស្នើសុំប្រភេទប័ណ្ណឥណទានវីសាផ្លាទីនីម និងប័ណ្ណឥណទានវីសាខ្លាស៊ីកក្នុងអំឡុងពេលកម្មវិធីប្រូម៉ូសិនជាមួយនឹងគោលការណ៍មិនមានទ្រព្យធានា(Unecured credit card) នឹងមិនគិតកម្រៃសេវាឆ្នាំដំបូងប្រសិនបើម្ចាស់ប័ណ្ណបានដំណើរការ(Activate)។
- អតិថិជនថ្មី ដែលស្នើសុំប្រភេទប័ណ្ណឥណទានវីសាផ្លាទីនីម និងប័ណ្ណឥណទានវីសាខ្លាស៊ីកជាមួយនឹងគោលការណ៍មានទ្រព្យធានា(Secured Credit Card) នឹងមិនគិតកម្រៃសេវាផ្ញើឯកសារចំពោះប័ណ្ណបានដំណើរការ (Activate) ជោគជ័យ។
- មិនកំណត់ចំនួនអតិថិជនថ្មីគ្រប់លក្ខខណ្ឌដែលបានស្នើសុំប្រភេទប័ណ្ណឥណទានវីសាខ្លាស៊ីក ថែមទាំងទទួលបានសំបុត្រ E-ticket ចំនួន១កូដ ដោយឥតគិតថ្លៃនៅរោងភាពយន្តLegend ពេលប័ណ្ណដំណើរការជោគជ័យ។ (លេខកូដសំបុត្រ E-ticket នៅរោងភាពយន្ត Legend នឹងត្រូវបានផ្ញើសារទៅកាន់លេខទូរស័ព្ទដែលបានចុះឈ្មោះនៅថ្ងៃធ្វើការបន្ទាប់ប្រសិនបើគ្រប់លក្ខខណ្ឌ)។
- អតិថិជនថ្មីគ្រប់លក្ខខណ្ឌ១០០នាក់ដំបូងដែលបានស្នើសុំប្រភេទប័ណ្ណឥណទានវីសាផ្លាទីនីម នឹងទទួលបានប័ណ្ណសមាជិកតម្លៃ ១០ដុល្លារ ចំនួន១ នៅកាហ្វេBrown បន្ទាប់ពីដំណើរការប័ណ្ណបានជោគជ័យ។
- ការផ្តល់ជូនមានចំនួនកំណត់ មកមុនបានមុនរហូតដល់អស់ពីស្តុក។
- ប្រសិនបើប័ណ្ណឥណទានវីសាត្រូវបានចេញក្នុងអំឡុងពេលកម្មវិធីប៉ុន្តែអតិថិជនស្នើសុំបិទ ឬលុបចោលប័ណ្ណក្នុងរយៈពេល៦ខែចាប់ពីថ្ងៃបើកដំណើរការប័ណ្ណ នឹងត្រូវបង់ថ្លៃសេវាប័ណ្ណតាមតារាងថ្លៃប័ណ្ណសម្រាប់រយៈពេលនីមួយៗ។

## 2- សម្រាប់គ្រប់ម្ចាស់ប័ណ្ណ៖

### a. ការផ្តល់ជូនបញ្ចុះតម្លៃ២ដុល្លារភ្លាមៗ លើកម្មវិធី foodanda app៖

- ទទួលបានការបញ្ចុះតម្លៃ២ដុល្លារភ្លាមៗជាមួយនឹងការកម្មង់អាហារយ៉ាងតិច៥ដុល្លារនៅលើកម្មវិធី foodpanda app។
- ប្រូម៉ូសិននេះអនុវត្តចំពោះម្ចាស់ប័ណ្ណឥណទានវីសាធនាគារ សាខមប៊ែង ខេមបូឌា ទាំងអស់នៅពេលជ្រើសរើសប័ណ្ណឥណទានវីសាធនាគារ សាខមប៊ែង ខេមបូឌា ជាវិធីសាស្រ្តទូទាត់សម្រាប់ការបញ្ជាទិញនៅលើកម្មវិធី foodpanda app។
- ម្ចាស់ប័ណ្ណដែលគ្រប់លក្ខខណ្ឌនឹងទទួលបានបញ្ចុះតម្លៃភ្លាមៗ នៅលើកម្មវិធីនៅពេលបញ្ចូលលេខកូដបញ្ចុះតម្លៃត្រឹមត្រូវ។
- ម្ចាស់ប័ណ្ណអាចរីករាយជាមួយនឹងការបញ្ចុះតម្លៃអតិបរមាបីដង ក្នុងកម្មវិធីប្រូម៉ូសិនមិនរួមបញ្ចូលកម្មវិធីប្រូម៉ូសិនដែលមាននៅក្នុងកម្មវិធី foodpanda app។
- ការផ្តល់ជូនអាចបញ្ចប់មុននេះ នៅពេលដែលកញ្ចប់ថវិកាអស់ហើយអ្នកនឹងត្រូវបានជូនដំណឹងដោយផ្ទាល់នៅលើកម្មវិធី foodpanda app ។

### b. ការផ្តល់ជូនលើសេវាបង់រំលស់អត្រាការប្រាក់0%

- មិនគិតសេវាបង់រំលស់ជាមួយរយៈពេល៦ខែ និង១២ខែ ក្នុងឱកាសខួបលើកទី១៥ របស់ធនាគារ សាខមប៊ែង ខេមបូឌា (អនុវត្តក្នុងអំឡុងពេល៣០ថ្ងៃដំបូង រហូតដល់ថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០២៤) ។
- បញ្ចុះ៥០%ថ្លៃសេវាសម្រាប់រយៈពេលកម្មវិធីប្រូម៉ូសិននៅមានសុពលភាព។
- ចំនួនទឹកប្រាក់ប្រតិបត្តិការត្រូវតែបំពេញតាមចំនួនអប្បបរមាសម្រាប់រយៈពេលនីមួយៗ។
- ប្រត្តិបត្តិការដែលគ្រប់លក្ខខណ្ឌត្រូវបំពេញទៅតាមគោលការណ៍និងលក្ខខណ្ឌរបស់គម្រោងបង់រំលស់អត្រាការប្រាក់ 0%។

### c. កម្មវិធីណែនាំ៖

- ទទួលបានសំបុត្រ E-ticket ចំនួន១គូ នៅរោងភាពយន្តLegend ចំពោះរាល់ប័ណ្ណបានដំណើរការ (Activate) ជោគជ័យ។
- សម្រាប់អ្នកណែនាំបានជោគជ័យដែលគ្រប់លក្ខខណ្ឌគឺ បន្ទាប់ពីអ្នកដែលត្រូវបានណែនាំបានដំណើរការប័ណ្ណ (Activate) ជោគជ័យ។
- សម្រាប់អ្នកណែនាំ គឺជាអតិថិជនបុគ្គលដែលកំពុងប្រើប្រាស់ផលិតផល ឬសេវាកម្មរបស់ ធនាគារ សាខមប៊ែង ខេមបូឌា

yាងហោចណាស់ មួយ ឬពីរ (ដែលមិនស្ថិតក្នុងការលុបចោល ឬចាក់សោសេវាកម្ម)។
- សម្រាប់អ្នកណែនាំ និងសម្រាប់ម្ចាស់ប័ណ្ណថ្មីអាចទទួលបានការផ្តល់ជូនជាច្រើនក្នុងពេលតែមួយប្រសិនបើពួកគេបំពេញគ្រប់លក្ខខណ្ឌ។
- លេខកូដសំបុត្រ E-ticket សម្រាប់មើលភាពយន្តនៅរោងភាពយន្ត Legend នឹងត្រូវបានផ្ញើសារទៅកាន់លេខទូរស័ព្ទដែលបានចុះឈ្មោះនៅថ្ងៃធ្វើការបន្ទាប់ចាប់ពីថ្ងៃដែលមានលក្ខខណ្ឌគ្រប់គ្រាន់។

## V. លក្ខខណ្ឌផ្សេងទៀត៖

- ប្រតិបត្តិការដែលជោគជ័យ (ម្ចាស់ប័ណ្ណនឹងទទួលបានសារជូនដំណឹងពីធនាគារ) ប៉ុន្តែបើក្នុងរយៈពេល៣០ថ្ងៃប្រតិបត្តិការទាំងនោះមិនបានកត់ត្រាចូលទៅក្នុងរបាយការណ៍នឹងត្រូវចាត់ទុកជាប្រតិបត្តិការមិនគ្រប់លក្ខខណ្ឌ។
- វិវាទ ការលុបចោល និង/ឬ ប្រតិបត្តិការបរាជ័យក្នុងអំឡុងពេលប្រូម៉ូសិននឹងត្រូវកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌ។
- រាល់ប្រតិបត្តិការដែលមានការសង្ស័យ ឬមិនមានលក្ខខណ្ឌគ្រប់គ្រាន់ដោយផ្អែកលើពេលវេលាទីតាំងរបស់ប្រតិបត្តិការ ឬកត្តាផ្សេងទៀតនឹងត្រូវកាត់ចេញពីប្រតិបត្តិការដែលមានលក្ខខណ្ឌមុន។ ធនាគារមានសិទ្ធិក្នុងការស្នើសុំអតិថិជនក្នុងការផ្តល់វិក័យប័ត្រហិរញ្ញវត្ថុដើម្បីបញ្ជាក់ពីភាពត្រឹមត្រូវរបស់ប្រតិបត្តិការ។ ក្នុងករណីដែលអតិថិជនខកខានមិនបានបង្ហាញពីភាពត្រឹមត្រូវរបស់ប្រតិបត្តិការនោះទេ ធនាគារនឹងធ្វើការកាត់ចេញតម្លៃសរុបនៃប្រតិបត្តិការទិញទំនិញដែលគ្រប់លក្ខខណ្ឌនោះ។
- ធនាគារ សាខមប៉ែង ខេមបូឌា មានសិទ្ធិបដិសេធនូវរាល់ពាក្យស្នើសុំដែលមិនគ្រប់លក្ខខណ្ឌ មិនច្បាស់លាស់ មិនគ្រប់គ្រាន់ និង/ឬ ឯកសារយោងមិនសមស្រប។

## VI. ព័ត៌មានបន្ថែម៖

- សម្រាប់ព័ត៌មានបន្ថែមអតិថិជនអាចអញ្ជើញមកកាន់សាខាណាមួយរបស់ធនាគារ សាខមប៉ែង ខេមបូឌា ឬទំនាក់ទំនងមកកាន់ភ្នាក់ងារបម្រើអតិថិជន៖ ០២៣ ២២៣ ៤២៣ និង ០៩៧ ៨ ២២៣ ៤២៣។
- ធនាគារ សាខមប៉ែង ខេមបូឌា ទទួលខុសត្រូវ ក្នុងការជូនដំណឹងទៅលើគោលការណ៍ និងលក្ខខណ្ឌនៃកម្មវិធីនេះ និងព័ត៌មានរបស់អតិថិជនដែលគ្រប់លក្ខខណ្ឌ (រួមមាន ឈ្មោះ លេខអត្តសញ្ញាណប័ណ្ណ/លិខិតឆ្លងដែននិងលេខបួនខ្ទង់ចុងក្រោយរបស់ប័ណ្ណចម្បងឥណទានវីសា) តាមរយៈគេហទំព័ររបស់ ធនាគារ សាខមប៉ែង ខេមបូឌា (sacombank.com.kh) ដោយមិនជូនដំណឹងជាមុន។

## VII. លក្ខខណ្ឌទូទៅ៖

- ធនាគារ សាខមប៉ែង ខេមបូឌា មិនទទួលខុសត្រូវ ចំពោះការមិនបានជូនដំណឹង ដោយសារបញ្ហាប្រព័ន្ធ Email អាសយដ្ឋាន ឬលេខទូរស័ព្ទដែលផ្តល់ដោយម្ចាស់ប័ណ្ណ ឬលិខិតជូនដំណឹងត្រូវបាត់ លួច ឬខូច។
- ធនាគារ សាខមប៉ែង ខេមបូឌា សូមរក្សាសិទ្ធិក្នុងការផ្លាស់ប្តូរលក្ខខណ្ឌទាំងនេះនៅពេលណាមួយដោយមិនចាំបាច់ធ្វើការជូនដំណឹងជាមុន។
- ក្នុងករណីមានវិវាទណាមួយកើតឡើងទាក់ទងនឹងកម្មវិធីប្រូម៉ូសិននេះ ធនាគារ សាខមប៉ែង ខេមបូឌា នឹងដោះស្រាយវិវាទនេះយ៉ាងសមស្របបំផុតទៅកាន់អតិថិជន ប្រសិនបើបរាជ័យក្នុងការដោះស្រាយវិវាទនោះនឹងត្រូវបានដោះស្រាយទៅតាមផ្លូវច្បាប់ដែលបានកំណត់។
- តាមរយៈការចូលរួមក្នុងកម្មវិធីនេះគ្រប់ម្ចាស់ប័ណ្ណទាំងអស់ត្រូវចាត់ទុកថាទទួល និងយល់ព្រមនូវគោលការណ៍ និងលក្ខខណ្ឌរបស់កម្មវិធី។